ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ ១៤១៨ អយក.បល

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០១៦

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**កម្មវត្ថុ:** សំណើសុំកំណត់គោលការណ៍ផ្តល់ប្រាក់លើកទឹកចិត្តជូននាយកសាលាចំណេះទូទៅ នាយកគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងគ្រូឧទ្ទេស ។

**យោង:** -តាមស្មារតីអង្គប្រជុំថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៥ នៅទីស្តីការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-លិខិតលេខ១០២៩ អយក.បល ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា នៅក្នុងកិច្ចប្រជុំពិភាក្សាគម្រោងថវិកាសម្រាប់វិស័យអប់រំឆ្នាំ២០១៦ កាលពីថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៥ រវាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ក្រសួងទាំងពីរបានឯកភាពលើការគ្រោងថវិកាសម្រាប់ចំណាយលើការលើកទឹកចិត្តនាយកសាលាចំណេះទូទៅ នាយកគ្រឹះស្ថានបណ្តុះបណ្តាលគ្រូនិងគ្រូឧទ្ទេស ដោយបានគ្រោងថវិកានៅក្នុងជំពូក៦៤ **គណនី៦៤០២ អនុគណនី៦៤០២១** ដែលមានទឹកប្រាក់ **១០.៤៤០.០០០.០០០ រៀល** ។

នៅក្នុងកិច្ចពិភាក្សា ក្រសួងអប់រំ យុវជន និងកីឡា បានលើកឡើងជាបឋមនូវការកំណត់ប្រាក់លើកទឹកចិត្តនាយកសាលាចំណេះទូទៅ នាយកគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងគ្រូឧទ្ទេស ដូចខាងក្រោម៖

| ល.រ | តួនាទី | ប្រាក់លើកទឹកចិត្ត |
|---|---|---|
| ១ | នាយកសាលាមត្តេយ្យសិក្សា | ១០០.០០០ រៀល/ខែ |
| ២ | នាយកសាលាបឋមសិក្សា | ១៤០.០០០ រៀល/ខែ |
| ៣ | នាយកអនុវិទ្យាល័យ | ១៤០.០០០ រៀល/ខែ |
| ៤ | នាយកវិទ្យាល័យ | ១៨០.០០០ រៀល/ខែ |
| ៥ | *នាយកវិទ្យាស្ថានជាតិអប់រំ* | *មិនទាន់បានកំណត់* |
| ៦ | នាយកវិទ្យាស្ថានជាតិអប់រំកាយនិងកីឡា | ២៤០.០០០ រៀល/ខែ |
| ៧ | នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ២៤០.០០០ រៀល/ខែ |
| ៨ | នាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម | ២០០.០០០ រៀល/ខែ |
| ៩ | នាយកសាលាគរុកោសល្យនិងវិក្រឹតការរាជធានី ខេត្ត | ២០០.០០០ រៀល/ខែ |
| ១០ | គ្រូឧទ្ទេសកម្រិតឧត្តមសិក្សា (បង្រៀននៅវិទ្យាស្ថានជាតិអប់រំ) | ១០០.០០០ រៀល/ខែ |
| ១១ | គ្រូឧទ្ទេសកម្រិតឧត្តម | ១០០.០០០ រៀល/ខែ |

| | | |
|---|---|---|
| ១២ | គ្រូឧទ្ទេសកម្រិតមូលដ្ឋាន | ៩០,០០០ រៀល/ខែ |
| ១៣ | គ្រូឧទ្ទេសកម្រិតបឋម | ៨០,០០០ រៀល/ខែ |

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យលទ្ធភាព និងសម្រេចលើគោលការណ៍ផ្តល់ប្រាក់លើកទឹកចិត្ត ដោយអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

<u>ចម្លងជូន:</u>
-ក្រសួងមុខងារសាធារណៈ:
" ដើម្បីជូនជ្រាបជាព័ត៌មាន "
-កាលប្បវត្តិ: ឯកសារ.នា.បុគ្គលិក